**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ.០៥០......សហវ.......

**សេចក្តីសម្រេច**

**ស្តីពី**

**ការបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយ**

**ស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៩៣ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលមាត្រា២ មាត្រា៣ និងមាត្រា៤ នៃព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៦ ស្តីពីការតម្លើងនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ ទៅជាអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍, តម្លើងនាយកដ្ឋានសហប្រតិបត្តិការ និងគ្រប់គ្រងបំណុល ទៅជាអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល និងបង្កើតនាយកដ្ឋានសវនកម្មបច្ចេកវិទ្យាព័ត៌មាន ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ១.-**

ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន ដែលមានសមាសភាពដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ចន្ស៊ី ចិស្សុត** | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (កសហវ) | ប្រធាន |
| ២- | ឯកឧត្តម | **ហែម វណ្ណឌី** | អនុរដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធាន |
| ៣- | ឯកឧត្តម | **ជា វុទ្ធី** | អគ្គលេខាធិការរងគណៈកម្មាធិការវិនិយោគកម្ពុជា នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | អនុប្រធាន |
| ៤- | ឯកឧត្តម | **ថេង បញ្ញាធន** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកអគ្គនាយកផែនការនៃក្រសួងផែនការ | អនុប្រធាន |
| ៥- | ឯកឧត្តម | **ហ៊ីង ថូរ៉ាក់ស៊ី** | រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |
| ៦- | លោកជំទាវ | **ម៉ែន ឆដា** | រដ្ឋលេខាធិការក្រសួងរ៉ែនិងថាមពល | សមាជិក |
| ៧- | ឯកឧត្តម | **នូ សុវត្ថិ** | រដ្ឋលេខាធិការក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ៨- | លោកជំទាវ | **តឹកវ៉េក គំរេ** | រដ្ឋលេខាធិការក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- | ឯកឧត្តម | **គីម ឆូច** | រដ្ឋលេខាធិការក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ១០- | ឯកឧត្តម | **ម៉ម អំណាត់** | រដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១១- | ឯកឧត្តម | **ទេព ធន** | អនុរដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១២- | ឯកឧត្តម | **សៅ សុភាព** | ទីប្រឹក្សាអមក្រសួង និងជានាយកខុទ្ទកាល័យក្រសួងបរិស្ថាន | សមាជិក |
| ១៣- | ឯកឧត្តម | **សុខ តុងហាប់** | អនុរដ្ឋលេខាធិការក្រសួងទេសចរណ៍ | សមាជិក |
| ១៤- | ឯកឧត្តម | **ជិន ម៉ាលីន** | អនុរដ្ឋលេខាធិការក្រសួងយុត្តិធម៌ | សមាជិក |
| ១៥- | ឯកឧត្តម | **ចាម ឫទ្ធី** | អនុរដ្ឋលេខាធិការក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ | សមាជិក |
| ១៦- | ឯកឧត្តម | **គង់ វិបុល** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានពន្ធដារ កសហវ | សមាជិក |
| ១៧- | ឯកឧត្តម | **ប្រាក់ សំអឿន** | អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនៃក្រសួងមហាផ្ទៃ | សមាជិក |
| ១៨- | ឯកឧត្តម | **គុណ ញឹម** | អគ្គនាយកនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា កសហវ | សមាជិក |
| ១៩- | ឯកឧត្តម | **ហាច រតនៈ** | អគ្គនាយកនៃអគ្គនាយកដ្ឋានថវិកា កសហវ | សមាជិក |
| ២០- | ឯកឧត្តម | **អ៊ឹម សិទ្ធីរ៉ា** | អគ្គនាយកនៃអគ្គនាយកដ្ឋានដោះស្រាយផលប៉ះពាល់ដោយសារគម្រោងអភិវឌ្ឍន៍ កសហវ | សមាជិក |
| ២១- | ឯកឧត្តម | **ប៉ែន ធីរុទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល កសហវ | សមាជិក |
| ២២- | លោក | **គីមធី កោមលី** | អគ្គនាយករងបច្ចេកទេសនៃធនាគារជាតិនៃកម្ពុជា | សមាជិក |
| ២៣- | លោក | **ស៊ីន ចាន់សេរីវុត្ថា** | អគ្គនាយករងនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល | សមាជិក |

| | | | | |
|---|---|---|---|---|
| ២៤- | លោក | **ចន ណារិទ្ធ** | អគ្គនាយករងនៃអគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ កសហវ | សមាជិក |
| ២៥- | លោក | **ស៊ាង ផល្លា** | ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម កសហវ | សមាជិក |

**ប្រការ២.**_

គណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន មានមុខងារ និងភារកិច្ចដូចខាងក្រោម÷

- ពិនិត្យឡើងវិញលើបទប្បញ្ញត្តិនៃច្បាប់ស្តីពីសម្បទាន និងច្បាប់ពាក់ព័ន្ធដទៃទៀត ព្រមទាំងរៀបចំ និងផ្តល់អនុសាសន៍ក្នុងការធ្វើវិសោធនកម្ម ឬ ធ្វើសំណើរៀបចំសេចក្តីព្រាងច្បាប់ថ្មីស្តីពីយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន តាមការចាំបាច់។
- រៀបចំសេចក្តីព្រាងអនុក្រឹត្យ ប្រកាស លិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងនីតិវិធីគ្រប់គ្រងប្រតិបត្តិការនៃគម្រោងវិនិយោគសាធារណៈតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- ពិនិត្យ និងអនុម័តបញ្ជីគម្រោងអាទិភាព និងលទ្ធផលនៃការសិក្សាលទ្ធភាពគម្រោងអាទិភាព រួមទាំងគម្រោងដែលនឹងដាក់ឱ្យអនុវត្តសាកល្បងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- បូកសរុបរបាយការណ៍ប្រចាំឆមាសនិងប្រចាំឆ្នាំ ជូនគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ពិនិត្យ និងសម្រេចដាក់ចេញវិធានការចាំបាច់នានា ដើម្បីដោះស្រាយបញ្ហាប្រឈម។ ក្នុងករណីមានវេទយិតភាព ត្រូវស្នើសុំការសម្រេចពីគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**ប្រការ៣.**_

គណៈកម្មការអន្តរក្រសួងដឹកនាំការអនុវត្តឯកសារគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន មានក្រុមការងារបច្ចេកទេស សម្រាប់សម្របសម្រួលការអនុវត្តគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជន ស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាលេខាធិការដ្ឋាន ដែលមានសមាសភាពដូចខាងក្រោម÷

| | | | | |
|---|---|---|---|---|
| ១- | ឯកឧត្តម | **ម៉ែន ធីរុទ្ធ** | អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល (អសប) | ប្រធាន |
| ២- | លោក | **រស់ បរម** | អគ្គនាយករងនៃអគ្គនាយកដ្ឋានថវិកា (អថ) | អនុប្រធាន |
| ៣- | លោក | **ម៉ាច សុភារ៉ា** | ប្រធាននាយកដ្ឋានគ្រប់គ្រងបំណុលនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | អនុប្រធាន |
| ៤- | លោក | **ធម្មី វិចិត្រ** | អនុប្រធាននាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ៥- | លោក | **ខិម ម៉ាក់ធារិទ្ធ** | អនុប្រធាននាយកដ្ឋានវិនិយោគនៃអគ្គនាយកដ្ឋានថវិកា | សមាជិក |
| ៦- | លោក | **ហ៊ុល មុណ្ណារ័ត្ន** | អនុប្រធាននាយកដ្ឋានសហប្រតិបត្តិការពហុភាគីនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | សមាជិក |
| ៧- | លោក | **ចាន់ សុមញ្ញារ័ត្ន** | អនុប្រធានការិយាល័យសហប្រតិបត្តិការពហុភាគីទី១នៃនាយកដ្ឋានសហប្រតិបត្តិការពហុភាគី (អសប) | សមាជិក |
| ៨- | | | ការិយាល័យសម្របសម្រួលការអភិវឌ្ឍផ្នែកឯកជននៃនាយកដ្ឋានវិនិយោគ (អថ) | សមាជិក |
| ៩- | | | ការិយាល័យវិភាគបំណុលនៃនាយកដ្ឋានគ្រប់គ្រងបំណុល (អសប) | សមាជិក |

**ប្រការ៤._**

ក្រុមការងារបច្ចេកទេស សម្រាប់សម្របសម្រួលការអនុវត្តគោលនយោបាយភាពជាដៃគូរវាងរដ្ឋ និងឯកជន មានភារកិច្ច ដូចខាងក្រោម÷

- សម្របសម្រួលនិងគ្រប់គ្រងប្រតិបត្តិការនៃគម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- ផ្តល់ការគាំទ្រខាងផ្នែកប្រតិបត្តិការដល់ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចចុះកិច្ចសន្យាជាមួយដៃគូឯកជន ក្នុងការកំណត់ វាយតម្លៃ រៀបចំរចនាសម្ព័ន្ធ ធ្វើកិច្ចលទ្ធកម្ម ចុះកិច្ចសន្យា និងគ្រប់គ្រងការអនុវត្តគម្រោង។
- ពិនិត្យ និងតាមដានលើកិច្ចប្រតិបត្តិនៅគ្រប់ដំណាក់កាលនៃវដ្តរបស់គម្រោងវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- ផ្តល់អនុសាសន៍ដល់គណៈកម្មការអន្តរក្រសួងលើការអនុវត្ត និងការធ្វើបច្ចុប្បន្នកម្មគោលនយោបាយស្តីពីការអភិវឌ្ឍយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- គ្រប់គ្រងមូលនិធិអភិវឌ្ឍន៍គម្រោង សម្រាប់គាំទ្រហិរញ្ញវត្ថុដល់ក្រសួង ស្ថាប័នពាក់ព័ន្ធលើការងារសិក្សា និងការរៀបចំគម្រោង ព្រមទាំងប្រតិបត្តិការនានាដើម្បីឈានដល់ការប្រគល់កិច្ចសន្យាអនុវត្តគម្រោងតាមយន្តការភាពជាដៃគូរវាងរដ្ឋ និងឯកជន។
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តវិធានការគោលនយោបាយ និងវិធានការដោះស្រាយបញ្ហាប្រឈម ព្រមទាំងរាយការណ៍លទ្ធផលវឌ្ឍនភាពនៃការអនុវត្តជូនគណៈកម្មការអន្តរក្រសួង។
- បំពេញភារកិច្ចពាក់ព័ន្ធផ្សេងទៀត តាមការកំណត់របស់ប្រធានគណៈកម្មការអន្តរក្រសួង។

**ប្រការ៥._**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៦._**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធ និងអគ្គាធិការនៃអគ្គាធិការដ្ឋាន អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ កញ្ញា ឆ្នាំ២០១៦

**ទេសរដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**...ត. អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច,ឯកឧត្តម, លោកជំទាវឧបនាយករដ្ឋមន្ត្រី

-ក្រសួងមុខងារសាធារណៈ

-ដូចប្រការ៦

-ឯកសារ-កាលប្បវត្តិ